# សេចក្តីប្រកាសព័ត៌មាន
# យុទ្ធនាការរយៈពេលពីរសប្តាហ៍ចូលរួមប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២១ ក្រោមប្រធានបទ “ព័ត៌មានដែលជាប្រយោជន៍សាធារណៈ”

ភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ -- ក្រុមការងារដើម្បីសេរីភាពសារព័ត៌មាន ដែលរួមមានអង្គការ-សមាគមអ្នកសារព័ត៌មាន និង អង្គការសង្គមស៊ីវិលសរុបចំនួន១៣ស្ថាប័ន បានរួមគ្នារៀបចំជាយុទ្ធនាការតាមបណ្តាញសង្គមរយៈពេលពីរសប្តាហ៍ក្នុងគោលបំណងឆ្លុះបញ្ចាំងពីសារសំខាន់ និងជំរុញឱ្យមានការចូលរួមពីសាធារណជនក្នុងការលើកកម្ពស់សេរីភាពសារព័ត៌មាន ។

យុទ្ធនាការនេះនឹងចាប់ផ្តើមពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១នេះ ដើម្បីចូលរួមប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកលោកឆ្នាំ២០២១ ក្រោមប្រធានបទរួម **“ព័ត៌មានដែលជាប្រយោជន៍សាធារណៈ”** ។ នៅក្នុងអំឡុងពេលនៃយុទ្ធនាការ សកម្មភាពមួយចំនួននឹងត្រូវអនុវត្តដោយបណ្តាស្ថាប័នដែលជាសមាជិកនៃក្រុមការងារនិងអ្នកពាក់ព័ន្ធ ព្រមទាំងការចូលរួមពីសំណាក់សាធារណជន ផងដែរ។ សកម្មភាពសំខាន់ៗទាំងនោះរួមមាន ៖

- ការបង្ហោះសារខ្លីៗអំពីសារសំខាន់នៃព័ត៌មានចំពោះប្រយោជន៍សាធារណៈ
- ការបង្ហោះវីដេអូស្តីពីសារសំខាន់នៃតួនាទីអ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ
- ការប្តូរ Facebook profile photo frame
- កិច្ចពិភាក្សាតាមវិទ្យុ និងបណ្តាញសង្គមលើប្រធានបទពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន
- កិច្ចពិភាក្សាពិសេសនៅថ្ងៃទី៣ ខែឧសភា ក្រោមប្រធានបទ **“សេរីភាពសារព័ត៌មាន និងកិច្ចសហប្រតិបត្តិការធ្វើឱ្យប្រសើរឡើង”** ដែលនឹងមានការអញ្ជើញចូលរួមរបស់វាគ្មិនដែលជាតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការជាតិ និងអន្តរជាតិដែលធ្វើការពាក់ព័ន្ធនឹងវិស័យសារព័ត៌មានផងដែរ។ លោកអ្នកអាចចូលរួមកិច្ចពិភាក្សាបានតាមរយៈតំណភ្ជាប់នេះ

  https://zoom.us/j/98102285503?pwd=OURUbzB2aHNNUnhtOGtaNWtYS1U2QT09

  Passcode: FP@21#0314 ។

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ហៅកាត់ថា ខេមបូចា) និងជាតំណាងក្រុមការងារដើម្បីសេរីភាពសារព័ត៌មាន មានប្រសាសន៍ថា៖ “អ្នកសារព័ត៌មានមានតួនាទីសំខាន់ណាស់នៅក្នុងសង្គមប្រជាធិបតេយ្យ ជាពិសេស នៅក្នុងស្ថានភាពដែលប្រទេសកម្ពុជាយើងកំពុងតែមានការឆ្លងរាលដាលជំងឺកូវីដ១៩នេះ ដែលចាំបាច់ត្រូវការអ្នកសារព័ត៌មានដែលមានតួនាទីក្នុងការរាយការណ៍ព័ត៌មានពិត និងទាន់ពេលវេលាជូនដល់ប្រជាពលរដ្ឋ ។ ការប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកលោកក្រោមប្រធាន

បទ **ព័ត៌មានដែលជាប្រយោជន៍សាធារណៈ** នៅឆ្នាំ ២០២១នេះ គឺពិតជាមានសារសំខាន់សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវរួមគ្នាលើកកម្ពស់សេរីភាពសារព័ត៌មាននិងផ្តល់តម្លៃសម្រាប់តួនាទីរបស់ពួកគាត់" ។

លោក អ៊ិត សុធឿត តំណាងក្រុមការងារដើម្បីសេរីភាពសារព័ត៌មានមួយរូបទៀត និងជានាយកស្តីទីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) មានប្រសាសន៍ថា៖ "ភាគីពាក់ព័ន្ធទាំងអស់ ពិសេសរាជរដ្ឋាភិបាលត្រូវតែធានាចំពោះសុវត្ថិភាព និងសន្តិសុខរបស់អ្នកសារព័ត៌មានគ្រប់រូបដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិសេរីភាពក្នុងការរាយការណ៍ព័ត៌មាន ពិសេសបទល្មើសក៏ដូចជាបញ្ហាអសកម្មនានាដែលកំពុងកើតមានឡើងនៅក្នុងសង្គមដោយមិនមានការភ័យខ្លាច ដើម្បីប្រយោជន៍សាធារណៈនិងធានាចំពោះសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប" ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**លោក ណុប វី** នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net
**លោក អ៊ិត សុធឿត** នាយកស្តីទីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
ទូរសព្ទ៖ ០១២ ៨៩១ ៥៤៥
អ៊ីមែល៖ isothoeuth@vodhotnews.com

ក្រុមការងារដើម្បីសេរីភាពសារព័ត៌មាន ដែលបានចូលរួមរៀបចំយុទ្ធនាការនេះរួមមាន៖

១. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
២. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៤. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
៥. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៦. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)
៧. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
៨. បណ្តាញយុវជនកម្ពុជា (CYN)
៩. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
១០. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
១១. មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
១២. អង្គការសមាគមផាងត្នោត (STT)
១៣. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)